# ការពិនិត្យពីសកម្មភាពផ្តល់ហិរញ្ញប្បទានដល់សហគ្រាសធុនតូច និងមធ្យម នៅកម្ពុជា[១]

## សាវតារ និងគោលបំណងនៃការសិក្សា

រដ្ឋាភិបាលកម្ពុជា បានអនុម័តវិធានការផ្នែកគោលនយោបាយមួយចំនួន ដើម្បីគាំទ្រ និងជំរុញសហគ្រាសធុនតូច និងមធ្យម (SMEs) ដោយបានកំណត់ថា វិស័យនេះសំខាន់ខ្លាំងណាស់សម្រាប់ជំរុញ និងរក្សាសន្ទុះសេដ្ឋកិច្ចរបស់កម្ពុជា ពីព្រោះ SME មានចំនួនច្រើនជាងគេ និងមានសក្តានុពលក្នុងការបង្កើតការងារ (អនុគណៈកម្មការ SME ឆ្នាំ២០០៥)។

ស្របតាមទិសដៅនៃ យុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាលដែលកំណត់ថា ការជំរុញ SMEs ជាផ្នែកសំខាន់មួយក្នុងការអភិវឌ្ឍវិស័យឯកជននោះ អនុគណៈកម្មការ SME ក៏ត្រូវបានបង្កើតឡើង ដើម្បីរួមសហការជាមួយដៃគូអភិវឌ្ឍន៍នានា រៀបចំនូវក្របខ័ណ្ឌអភិវឌ្ឍន៍ SME សម្រាប់ធ្វើជាផែនទីបង្ហាញផ្លូវក្នុងការបង្កើត SMEs[២] នៅទូទាំងប្រទេស។ ក្របខ័ណ្ឌនេះមានគោលដៅជំរុញការអភិវឌ្ឍ SME តាមរយៈ (១)ការកែលំអក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តិ (២)ការជួយសម្រួលលទ្ធភាពទទួលបានហិរញ្ញវត្ថុ (៣)ការធ្វើពិពិធកម្ម និងការសម្របសម្រួលសកម្មភាពជួយគាំទ្រដល់ SME និង (៤)ការសម្របសម្រួលគោលនយោបាយ។

អត្ថបទនេះ ផ្តោតលើលទ្ធភាព SME ក្នុងការទទួលបានហិរញ្ញវត្ថុ និងពិនិត្យជាក់លាក់ពីចំណុចខ្វះខាតក្នុងកម្មវិធីផ្តល់ហិរញ្ញប្បទានដល់ SME ជាពិសេស ចាប់តាំងពីពេលបង្កើតក្របខ័ណ្ឌអភិវឌ្ឍន៍SMEក្នុងឆ្នាំ២០០៥។អត្ថបទនេះចែកចេញជាផ្នែកផ្សេងៗមួយចំនួនទៀត ដូចតទៅ៖ ផ្នែកទី២ បង្ហាញពីសកម្មភាពផ្សេងៗដែលបានលើកឡើងនៅក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍ SME ដើម្បីកែលំអលទ្ធភាព SME ក្នុងការទទួលបានហិរញ្ញវត្ថុ។ ផ្នែកទី៣ ជាការពិនិត្យឡើងវិញលើឯកសារមានស្រាប់ ស្តីពីឧបសគ្គចំពោះការផ្តល់ហិរញ្ញប្បទានដល់ SME និងការពិនិត្យជាទូទៅលើស្ថានភាពហិរញ្ញប្បទាននៃ SME និងកំហិតនានានៅកម្ពុជា។ ផ្នែកទី៤ អធិប្បាយពីវឌ្ឍភាពក្នុងការកែលំអហិរញ្ញប្បទានដល់ SME នៅក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍ SME។ ផ្នែកទី៥ បង្ហាញពីសេចក្តីសន្និដ្ឋាន និងអនុសាសន៍ ដើម្បីជួយសម្រួលដល់ដំណើរការអភិវឌ្ឍ SME។

## បណ្តាសកម្មភាពមានលើកឡើងក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍ SME ដើម្បីកែលំអលទ្ធភាព SME ក្នុងការទទួលបានហិរញ្ញវត្ថុ

ដើម្បីលើកកម្ពស់លទ្ធភាព SME ក្នុងការទទួលបានហិរញ្ញវត្ថុសម្រាប់ធ្វើទុនបង្វិល និងវិនិយោគនោះ ក្របខ័ណ្ឌអភិវឌ្ឍន៍ SME បានផ្តោតលើបញ្ហាធំៗបួន៖

- **វត្ថុបញ្ចាំ និងការចុះបញ្ជីដីធ្លី៖** ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា រំពឹងថា អាចឲ្យធនាគារប្រើចលនទ្រព្យជាវត្ថុបញ្ចាំបាន។ ការពន្លឿន និងកាត់បន្ថយបន្ទុកចំណាយលើការចុះបញ្ជីដីធ្លី ចាំបាច់ខ្លាំងណាស់ដើម្បីលើកកម្ពស់ការប្រើប្រាស់ដីធ្លីជាវត្ថុបញ្ចាំ។
- **ភតិសន្យាហិរញ្ញវត្ថុ[៣]៖** អវត្តមានក្របខ័ណ្ឌច្បាប់ដ៏ជាក់លាក់សម្រាប់ឲ្យ SME ទទួលបានភតិសន្យាហិរញ្ញវត្ថុ បានរារាំងដល់ធនាគារ និងស្ថាប័នហិរញ្ញវត្ថុ ក្នុងការបង្កើតបែបបទសម្រួលការជួលសម្ភារៈសម្រាប់បម្រើ SMEs។
- **ការចែករំលែកព័ត៌មានឥណទាន៖** បរិយាកាសកម្ចីមានហានិភ័យខ្ពស់នៅកម្ពុជា វាជាប់ទាក់ទងខ្លាំងទៅនឹងអវត្តមាននៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានជាផ្លូវការ ដែលជំរុញឲ្យធនាគារត្រូវប្រើវត្ថុបញ្ចាំដើម្បីកាត់បន្ថយហានិភ័យផុសចេញពីបញ្ហាប្រភពព័ត៌មានមិនដូចគ្នា។ វត្តមានប្រព័ន្ធចែករំលែកព័ត៌មានដ៏ល្អមួយ អាចលើកទឹកចិត្តឲ្យធនាគារទាំងអស់ចូលរួមនៅក្នុង ប្រព័ន្ធព័ត៌មានឥណទានដោយស្ម័គ្រចិត្ត។
- **គណនេយ្យសាមញ្ញ៖** ក្រុមប្រឹក្សាគណនេយ្យជាតិ បានបង្កើតគោលការណ៍ណែនាំ និងប្រព័ន្ធរាយការណ៍ហិរញ្ញវត្ថុបែបសាមញ្ញដែលអាចឲ្យSMEsកត់ត្រាបានកាន់តែប្រសើរនិងផ្តល់ព័ត៌មានបានសព្វគ្រប់ តាមការតម្រូវរបស់ធនាគារ។ ក្នុងនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) បានអនុវត្តហើយនូវ កម្មវិធីបណ្តុះបណ្តាល និងផ្សព្វផ្សាយព័ត៌មានសម្រាប់ SMEs ។

ដើម្បីពង្រឹងទំនាក់ទំនងរវាងរដ្ឋាភិបាល និងវិស័យឯកជន មានការបង្កើត ក្រុមការងារផ្នែកការផលិត និង SME ឡើងសម្រាប់ធ្វើការជាមួយអនុគណៈកម្មការ SME ។ អនុគណៈកម្មការ និងក្រុមការងារ ដោយមានការសម្របសម្រួលពីលេខាធិការដ្ឋាន SME[៤] បានអនុវត្តផែនការការងារដូចគ្នា ពោលគឺការដោះស្រាយបញ្ហាវត្ថុបញ្ចាំមិនគ្រប់គ្រាន់ និងកង្វះសមត្ថភាពរបស់ SME ដើម្បីកែលំអលទ្ធភាពរបស់ពួកគេ ក្នុងការទទួលបានហិរញ្ញវត្ថុ។ ក្នុងនេះ សកម្មភាពដែលលើកឡើងដោយលេខាធិការដ្ឋាន SME រួមមានការបង្កើតវេទិកាធនាគារ និង SME ការបណ្តុះបណ្តាលប្រតិបត្តិករ SME លើការគ្រប់គ្រងហិរញ្ញវត្ថុ និងធ្វើផែនការអាជីវកម្ម ការធ្វើ

---

[១] អត្ថបទនេះ រៀបរៀងដោយលោក លោក កែវ សុជាតិ អ្នកស្រាវជ្រាវក្នុងកម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ នៃវិទ្យាស្ថាន CDRI។

[២] ក្របខ័ណ្ឌអភិវឌ្ឍន៍ SME បែងចែកប្រភេទសហគ្រាសតាម ចំនួននិយោជិតធ្វើការពេញម៉ោង (ធុនមីក្រូ <១០នាក់ ធុនតូច ពី ១០-៥០នាក់ ធុនមធ្យម ពី ៥១-១០០នាក់) ឬ ទ្រព្យសម្បត្តិក្រៅពីដីធ្លី (ធុនមីក្រូ <៥០.០០០ដុល្លារ ធុនតូច ៥០.០០០-២៥០.០០០ដុល្លារ និងធុនមធ្យម ២៥០.០០០-៥០០.០០០ដុល្លារ)។

[៣] ភតិសន្យាហិរញ្ញវត្ថុ អាចឲ្យសហគ្រាស ជួល និងទីបំផុតទិញបរិក្ខារចាំបាច់ៗ ដូចជា ទ្រព្យសកម្មជាប់លាប់ជាដើម។

[៤] លេខាធិការដ្ឋានSMEដែលបង្កើតឡើងដោយអនុគណៈកម្មការSMEបានផ្តល់ជាយន្តការសម្របសម្រួលខាងក្នុងស្ថាប័នមួយ សម្រាប់ការអនុវត្តក្របខ័ណ្ឌអភិវឌ្ឍន៍ SME និងផែនទីបង្ហាញផ្លូវ ដើម្បីជំរុញការអភិវឌ្ឍ SME។

ពិពិធកម្មឧបករណ៍ហិរញ្ញវត្ថុ និងការរៀបចំប្រព័ន្ធគណនេយ្យនិងហិរញ្ញវត្ថុបែបសាមញ្ញសម្រាប់ SMEs។

## ការពិនិត្យទូទៅលើវិស័យហិរញ្ញវត្ថុ ហិរញ្ញប្បទាន SME និងកំហិតផ្សេងៗ

### *ការពិនិត្យលើឯកសារមានស្រាប់*

នីតិវិធីធនាគារស្មុគស្មាញ អត្រាការប្រាក់ខ្ពស់ និងកំហិតផ្សេងៗ ផុសចេញពីកម្ចីមានរយៈពេលខ្លី[៩] ដែលជាលក្ខណៈសម្គាល់នៃ វិស័យហិរញ្ញវត្ថុក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដូចជាប្រទេសកម្ពុជា អាចកើតមានឡើងដោយសារ ធនាគារព្យាយាមការពារខ្លួន ទល់នឹងហានិភ័យបង្កដោយបញ្ហាប្រភពព័ត៌មានមិនដូចគ្នា (Beck & Asli 2006; Beck 2007)។ ដូច្នេះ ធនាគារក៏បានដាក់កម្រិតកំណត់លើ បរិមាណឥណទានដែលផ្ដល់ឲ្យក្នុងកម្រិតអត្រាការប្រាក់ជាក់លាក់ណាមួយ ដោយមានការតម្រូវឲ្យដាក់វត្ថុបញ្ចាំជាទ្រព្យជាប់លាប់ និងលក្ខខណ្ឌបង្វិលសងវិញ (Petrick 2004)។

Oum *et al.* (2011) បានវែកញែកថា នៅកម្ពុជា អវត្តមាននៃប្រព័ន្ធធានាខុសត្រូវ និងយន្តការកាត់បន្ថយហានិភ័យចំពោះធនាគារ បាននាំឲ្យមានប្រហែល ៩៦%នៃសំណើសុំកម្ចីពីធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ សុទ្ធតែត្រូវផ្អែកលើវត្ថុបញ្ចាំ។ ចំណុចនេះបញ្ជាក់ថា ធនាគារបានប្រើការតម្រូវឲ្យដាក់វត្ថុបញ្ចាំ ដើម្បីដាក់កម្រិតកំណត់លើឥណទានផ្ដល់ឲ្យ SMEs។ ក្នុងចំណោមសហគ្រាសបានធ្វើអង្កេតក្នុងការសិក្សានេះ មានជាង ១៥% បានរាយការណ៍ថា ពួកគេមិនអាចពង្រីកអាជីវកម្មបានដោយសារមានហិរញ្ញវត្ថុមិនគ្រប់គ្រាន់។ ច្បាស់ហើយ ទោះបីរដ្ឋាភិបាលបានប្រឹងប្រែងដូច្នេះក្ដី ក៏លទ្ធភាពទទួលបានហិរញ្ញវត្ថុ នៅតែជាឧបសគ្គចម្បងមួយចំពោះការអភិវឌ្ឍ SME។

### *ស្ថានភាពនៅកម្ពុជា*

ក្នុងអំឡុងឆ្នាំ២០០៥-២០០៩ អត្រាការប្រាក់ប្រចាំឆ្នាំ មានប្រហែល ១៦% សម្រាប់កម្ចី និង ៥% សម្រាប់ប្រាក់បញ្ញើ ប៉ុន្តែអត្រាការប្រាក់លើកម្ចីជាប្រាក់ដុល្លាររបស់ MFIs ខ្ពស់មួយជាពីរជាងអត្រាកំណត់ដោយធនាគារ(តារាង១)។ហានិភ័យបង្កដោយចំណាត់ថ្នាក់ឥណទានមិនប្រាកដប្រជារបស់អ្នកខ្ចីប្រាក់ និងការស្វែងរកប្រាក់ចំណេញរបស់ស្ថាប័នហិរញ្ញវត្ថុ ជាហេតុផលចម្បងពីរ នៃអត្រាការប្រាក់ខុសៗគ្នានៅប្រទេសកម្ពុជា។

ធនាគារពាណិជ្ជក្នុងស្រុក ផ្ដល់ត្រឹមតែ ១% នៃទុនបង្វិល និង ១,៧% នៃមូលធនវិនិយោគប៉ុណ្ណោះទៅឲ្យ SMEs (IFC 2010) ដោយសារជាសំខាន់ ស្ថាប័នហិរញ្ញវត្ថុនៅកម្ពុជាខ្វះសមត្ថភាពប្រមូលព័ត៌មានឥណទាន (Sohn 2010; Harner 2003) ហើយសេវាកម្មធនាគារ អាចប្រើប្រាស់បានភាគច្រើនតែនៅតំបន់ទីក្រុង ដោយក្នុងនោះ ៦២% នៃសាខាធនាគារនានាស្ថិតនៅក្នុងរាជធានីភ្នំពេញ និងមានប្រជាជនតិចជាង ៨% ប្រើប្រាស់សេវាហិរញ្ញវត្ថុ និងផលិតផលអំពីធនាគារ និង MFIs។ តួលេខទាំងនេះបង្ហាញថា ការចូលមិនសូវដល់ប្រជាជនជាទូទៅ នៅតែជាចំណុចខ្វះខាតមួយនៃវិស័យធនាគារនៅកម្ពុជា។

តារាង ១៖ អត្រាការប្រាក់ប្រចាំឆ្នាំ (ជា %) នៃកម្ចីជាប្រាក់ដុល្លារ

| | 2005 | 2006 | 2007 | 2008 | 2009 |
|---|---|---|---|---|---|
| ធនាគារ | 16.20 | 16.37 | 15.83 | 16.08 | 15.56 |
| MFIs | 31.75 | 30.70 | 28.10 | 29.18 | 27.39 |

ប្រភព៖ NBC (2009) មានចុះនៅក្នុងការសិក្សារបស់ Sohn (2010)

បើទោះជាធនាគារពាណិជ្ជ និង MFIs មួយចំនួន មានបែបបទផ្ដល់កម្ចីទៅឲ្យ SMEs ក៏ដោយ ក៏ពួកគេបន្តតម្រង់ទិសផលិតផល និងសេវាកម្មរបស់ខ្លួន ទៅរកការជួញដូរជាមួយក្រុមហ៊ុនពហុជាតិ ដែលហុចផលចំណេញច្រើនជាង (Sohn 2010)។ បើសិនមិនមានព័ត៌មានគួរឲ្យជឿជាក់ពីអ្នកខ្ចីទេ ធនាគារតែងដាក់លក្ខខណ្ឌតឹងរឹងលើកម្ចីផ្ដល់ឲ្យ SME ដើម្បីកាត់បន្ថយហានិភ័យបង្កឡើងដោយភាពមិនច្បាស់លាស់លើលក្ខណៈគួរទទួលបានឥណទាន។ ធនាគារ និង MFIs នៅតែទាមទារឲ្យ SMEs ដាក់ប័ណ្ណកម្មសិទ្ធិដីជាវត្ថុបញ្ចាំ និងត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

- មានឋានៈជាសហគ្រាសផ្លូវការ (បានចុះបញ្ជី) -- ផ្ដល់ឯកសារថតចម្លងផ្សេងៗ រួមមាន អត្តសញ្ញាណប័ណ្ណ ប៉ាតង់ អាជ្ញាប័ណ្ណ
- ប្រើប្រាក់កម្ចីដើម្បីចាប់ផ្ដើម ឬពង្រីកអាជីវកម្ម
- បានដាក់ជូនពិនិត្យនូវផែនការអាជីវកម្ម និងកំណត់ត្រាហិរញ្ញវត្ថុ
- មានបទពិសោធន៍ និងជំនាញគ្រប់គ្រង៖ អ្នកខ្ចីដែលមិនមានបទពិសោធន៍ធ្វើអាជីវកម្ម មិនទំនងអាចទទួលបានកម្ចី ឬអាចផ្ដល់កំណត់ត្រាហិរញ្ញវត្ថុនោះទេ
- មានទុន ២០% នៃមូលធនវិនិយោគសរុប
- ផ្ដល់វត្ថុបញ្ចាំ (ប័ណ្ណកម្មសិទ្ធិដី អចលនទ្រព្យ)

ប្រព័ន្ធចែកចាយព័ត៌មានឥណទាន (CIS) ផ្អែកលើវែបសាយសាកល្បងមួយ បានចាប់ផ្ដើមនៅកម្ពុជា នៅឆ្នាំ២០០៦ និងមិនទាន់បានពង្រីកបន្ថែមទេ ដោយសារការប្រើប្រាស់នៅមានតិចក្នុងវិស័យធនាគារនៅកម្ពុជា (Sohn 2010)។ CIS មានភាគច្រើនតែព័ត៌មានអវិជ្ជមានលើអ្នកខ្ចីប្រាក់ ប៉ុន្តែធនាគារត្រូវការទាំងព័ត៌មានអវិជ្ជមាន និងវិជ្ជមាន ដើម្បីអាចវាយតម្លៃបានកាន់តែគ្រប់ជ្រុងជ្រោយពី ភាពអាចទុកចិត្តបានផ្នែកឥណទានរបស់អ្នកខ្ចី។ បញ្ហាចោទលើ CIS មួយទៀតនាបច្ចុប្បន្ន គឺសមាជិកភាពមានលក្ខណៈស្ម័គ្រចិត្ត។ ម្យ៉ាងទៀត ប្រព័ន្ធកំណត់ភាពគួរទុកចិត្តផ្នែកឥណទាន ក៏មិនទាន់បានដាក់អនុវត្ត ដោយសារកង្វះព័ត៌មានស្ដីពីរបាយការណ៍ហិរញ្ញវត្ថុរបស់ SMEs ធ្វើឲ្យធនាគារ និងស្ថាប័នហិរញ្ញវត្ថុ ពិបាកនឹងបង្កើតគំរូផ្ដល់ឥណទានមួយដែលអាចប្រើកើតជាមួយ SMEs។ សមាជិកភាពខានមិនបាន នៅក្នុងការិយាល័យធ្វើចំណាត់ថ្នាក់ឥណទាន ជាជម្រើសដ៏សក្ដិសិទ្ធិមួយសម្រាប់កែលំអបែបបទអនុវត្តរបស់ CIS។ នៅពេលមានដំណើរការពេញលេញហើយ ការិយាល័យធ្វើចំណាត់ថ្នាក់ឥណទាននឹង

[៩] អាជីវកម្មធុនតូច អាចទទួលបានតែឥណទានរយៈពេលខ្លីប៉ុណ្ណោះ។ កម្ចីរយៈពេលវែងដែលមានអត្រាការប្រាក់ប្រកួតប្រជែងល្អ គឺភាគច្រើនពួកអាជីវកម្មធំៗសុំខ្ចីផ្ដាច់មុខហើយ។

ជួយសម្រួលដល់ប្រព័ន្ធធានាខុសត្រូវផ្នែកឥណទាន ដែលត្រូវអនុវត្តដោយរដ្ឋាភិបាល និងដៃគូអភិវឌ្ឍអន្តរជាតិនានា។

ថ្មីៗនេះ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និង MEF បានព្រមព្រៀងលើមូលនិធិធានាខុសត្រូវឥណទានមួយ មានទឹកប្រាក់ ២៥លានដុល្លារ ដើម្បីចាប់អនុវត្តគ្រោងការណ៍ចែករំលែកហានិភ័យ (RSF) មួយដែលគេហៅថា កម្មវិធីចែករំលែកហានិភ័យមីក្រូហិរញ្ញវត្ថុ។ តាមនេះ ៥០% នៃកម្ចីដែលធនាគារ និង MFIs ផ្តល់ទៅឲ្យ SMEs នឹងមានកម្មវិធីនេះជួយធានាខុសត្រូវ ហើយហានិភ័យនៅសល់នឹងត្រូវរ៉ាប់រងដោយ MFIs និងធនាគារ[៦]។ ប៉ុន្តែធនាគារ និង MFIs នៅតែបន្តទាមទារនូវឯកសារស្តង់ដារសម្រាប់កម្ចី ពីព្រោះសមត្ថភាពរបស់អ្នកខ្ចីក្នុងការរៀបចំផែនការអាជីវកម្ម និងរបាយការណ៍ហិរញ្ញវត្ថុសមស្រប គេចាត់ទុកវាជាកត្តាកំណត់នៃ RSFs ប្រកបដោយជោគជ័យនៅតាមប្រទេសកំពុងអភិវឌ្ឍដទៃទៀត។

## ការពិនិត្យឡើងវិញពីក្របខ័ណ្ឌអភិវឌ្ឍន៍ SME

រដ្ឋាភិបាល សម្រេចបានវឌ្ឍនភាពក្នុងដំណើរការកែលំអហិរញ្ញប្បទានដល់ SME នៅក្នុង ក្របខ័ណ្ឌអភិវឌ្ឍន៍ SME ដែលមានជាសង្ខេប៖

- ក្រុមប្រឹក្សាគណនេយ្យជាតិ បានចេញផ្សាយគំរូរបាយការណ៍ហិរញ្ញវត្ថុបែបសាមញ្ញសម្រាប់ SMEs និងបានផ្តល់កម្មវិធីបណ្តុះបណ្តាលមួយ សម្រាប់អ្នកវិជ្ជាជីវៈខាងគណនេយ្យ និង SMEs។
- អគ្គនាយកដ្ឋានពន្ធដារ បានចេញផ្សាយ គំរូថ្មីនៃលិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំ និងសេចក្តីណែនាំសម្រាប់ការបំពេញលិខិតនេះ។
- ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា បានអនុម័តចេញក្នុងឆ្នាំ២០០៧ ដើម្បីកំណត់នូវយន្តការប្រកបដោយប្រសិទ្ធភាពមួយសម្រាប់កម្ចីមានដាក់របស់បញ្ចាំ។
- ច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ បានអនុម័តចេញនៅឆ្នាំ២០០៩ ដើម្បីបង្កើតនូវក្របខ័ណ្ឌអំណោយផលមួយសម្រាប់ឲ្យធនាគារផ្តល់សេវាកម្មភតិសន្យាហិរញ្ញវត្ថុ ទៅដល់ SMEs ដែលមានដាក់វត្ថុបញ្ចាំតិចតួច។
- ធនាគារជាតិនៃកម្ពុជា បានអនុម័តចេញនូវប្រកាសស្តីពីការប្រើប្រាស់ និងការការពារព័ត៌មានឥណទានដែលផ្តល់សិទ្ធិឲ្យធនាគារឯកទេស និងធនាគារពាណិជ្ជ ធ្វើអាជីវកម្មភតិសន្យាហិរញ្ញវត្ថុ ក្រោមច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ។

ទោះមានកិច្ចប្រឹងប្រែងដូចខាងលើក្តី សហគ្រាសកម្ពុជាមួយភាគធំប្រមាណ ៧២% មានលក្ខណៈជាអាជីវកម្មគ្រួសារ មានបុគ្គលិកពីមួយនាក់ ដល់ បីនាក់ (NIS 2009)។ ក្នុងចំណោម ៥០៥.១៣៤សហគ្រាស មានប្រហែល ៣,៥% ប៉ុណ្ណោះ ដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម នៅឆ្នាំ២០១១ (NIS 2012) គឺមានន័យថា សហគ្រាសភាគច្រើនស្ថិតក្នុងវិស័យមិនផ្លូវការ ដែលរារាំងពួកគេមិនឲ្យទទួលបានហិរញ្ញវត្ថុ ព្រោះធនាគារ និង MFIs តម្រូវឲ្យ SMEs មានលក្ខណៈស្របច្បាប់នៅពេលស្នើសុំប្រាក់កម្ចី។ SMEs រក្សាឋានៈមិនផ្លូវការនេះ ដោយសារគេយល់ឃើញថា ការអនុវត្តតាមរបៀបរបបគណនេយ្យស្តង់ដារមានភាពស្មុគស្មាញ និងមិនចាំបាច់ (IFC 2010)។ ម្យ៉ាងទៀតមាន SMEs ខ្លះ ចង់រក្សាកំណត់ត្រាហិរញ្ញវត្ថុបែបមិនផ្លូវការ ដែលអាចឲ្យពួកគេលាក់បាំងប្រាក់ចំណូល និងចំណេញពិត ពីអាជ្ញាធរពន្ធដារ ដើម្បីកាត់បន្ថយបំណុលពន្ធ[៧]។

ទោះជា SMEs ភាគច្រើន (ទាំងចុះបញ្ជីហើយ និងមិនទាន់ចុះបញ្ជី) មានរៀបចំរបាយការណ៍ចំណេញខាតប្រចាំខែក្តី ក៏ពួកគេមិនបានប្រើទម្រង់ស្តង់ដារអ្វីមួយទេ ព្រោះយល់ឃើញថាកំណត់ត្រាហិរញ្ញវត្ថុផ្លូវការមានលក្ខណៈស្មុគស្មាញ ឬមិនចាំបាច់ (IFC 2010; រូបភាព ១)។ កំណត់ត្រាហិរញ្ញវត្ថុផ្លូវការ ជាតម្រូវការស្តង់ដារមួយរបស់ធនាគារ ហើយប្រសិនបើមិនមានរបាយការណ៍នេះទេ SMEs មិនអាចទទួលបានឥណទានពីស្ថាប័នហិរញ្ញវត្ថុឡើយ។ ក្រៅពីការអនុវត្តតាមលក្ខខណ្ឌនេះ SMEs ត្រូវគោរពតាមនីតិវិធីស្តង់ដារជាច្រើនទៀត ជាពិសេស តម្រូវការវត្ថុបញ្ចាំ ដែលជាកត្តាចម្បងគេ រារាំង SME មិនឲ្យទទួលបានហិរញ្ញវត្ថុ។

SMEs មានការលំបាកនឹងទទួលបានហិរញ្ញវត្ថុ ដើម្បីទូទាត់ចំណាយជួលបរិក្ខារសំខាន់ៗ ដូចជា កុំព្យូទ័រ គ្រឿងចក្រ និងរថយន្ត ព្រោះសេវាកម្ម និងផលិតផលរបស់ MFIs និងធនាគារនៅកម្ពុជា មិនគ្របដណ្តប់លើកម្ចីភតិសន្យាទេ (IFC 2011)។ តាមរយៈភតិសន្យាហិរញ្ញវត្ថុ សហគ្រាសធុនតូច និងមធ្យមនានាអាចមានទុនសម្រាប់ជួលបរិក្ខារមកប្រើការ និងបង់ផ្តាច់ទិញយកតែម្តង។ អ្នកជួលត្រូវបង់ប្រាក់ជាទៀងទាត់ (ប្រាក់ដើម និងការប្រាក់) ក្នុងរយៈពេលកំណត់មួយ ហើយនៅចុងបញ្ចប់អាចទទួលបានរបស់នោះផ្តាច់តែម្តង។ អត្ថប្រយោជន៍នៃភតិសន្យា គឺ (១) មិនទាមទារវត្ថុបញ្ចាំ ឬរបាយការណ៍ហិរញ្ញវត្ថុ (២) ផ្តល់ហិរញ្ញប្បទាន សម្រាប់ការទិញទ្រព្យសកម្មដ៏ចាំបាច់នានា និង (៣) ទប់ទល់នឹងលទ្ធភាពបង្ខិលមូលនិធិខុសគោលដៅ ពេល

រូបភាព ១៖ ការគ្រប់គ្រងហិរញ្ញវត្ថុ នៃ ១២០ SMEs នៅក្នុងអង្កេត




ប្រភព៖ Tong (2011)

[៦] មិនមានព័ត៌មានលំអិតបន្ថែមពីគម្រោងនេះទេ។ ព័ត៌មាននេះ ផ្អែកលើច្បាប់ស្តីពីថវិកាជាតិ ឆ្នាំ២០១១ (មាត្រា ១៣) និងភស្តុតាងខ្លះៗពី MEF។

[៧] សម្ភាសន៍ជាមួយ មន្ត្រីឥណទាននៅ ធនាគារអភិវឌ្ឍន៍ជនបទ និង លេខាធិការដ្ឋាន SME នៅខែឧសភា ២០១១។

គឺ រឹងប៉ឹងជាងទុនបង្វិលដែលគេអាចលក់ចេញបាន។ សម្រាប់សហគ្រិន ដែលមិនអាចបំពេញបានតាមការតម្រូវជាធម្មតារបស់ធនាគារឲ្យដាក់វត្ថុបញ្ចាំនោះ ភតិសន្យា គឺជាជម្រើសមួយទៀតដើម្បីដោះស្រាយហិរញ្ញវត្ថុ។ ដូច្នេះ ភតិសន្យាអាចផ្ដល់អត្ថប្រយោជន៍រយៈពេលវែងសម្រាប់វិស័យ SME។

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ហិរញ្ញប្បទាន SME ប្រែប្រួលប្រសើរឡើងមួយកម្រិត ចាប់តាំងពីមានការបង្កើតក្របខ័ណ្ឌអភិវឌ្ឍន៍ SME ប៉ុន្តែដំណើរការដោះស្រាយបញ្ហាសំខាន់ៗបួន ដែលរារាំងលទ្ធភាពទទួលបានហិរញ្ញវត្ថុរបស់ SME ដូច អនុគណៈកម្មការ SME បានកំណត់នោះ វានៅយឺតយ៉ាវ។ ដីធ្លី នៅតែជាវត្ថុបញ្ចាំ ដែលស្ថាប័នហិរញ្ញវត្ថុនានាតែងតម្រូវឡើង ហើយបច្ចុប្បន្នពុំឃើញមានភស្តុតាងជាក់ស្ដែងណាមួយបង្ហាញថា ធនាគារ ឬ MFIs ទទួលយកចលនទ្រព្យជាវត្ថុបញ្ចាំនោះទេ។ ប្រព័ន្ធព័ត៌មានឥណទាន នៅខ្វះខាតច្រើនណាស់ដើម្បីក្លាយជាប្រព័ន្ធពេញលេញតាមច្បាប់ ដោយសារភាពអនុវត្តបានជាក់ស្ដែងនៅមានកម្រិត សមាជិកភាពមានលក្ខណៈជាការស្ម័គ្រចិត្ត ហើយហេដ្ឋារចនាសម្ព័ន្ធទន់ និងរឹង ក៏នៅខ្វះខាត។ ភតិសន្យាហិរញ្ញវត្ថុសម្រាប់ SME នៅមានតិចតួចណាស់ ទោះជាច្បាប់ស្ដីពី ភតិសន្យាហិរញ្ញវត្ថុ បានដាក់អនុវត្តតាំងពីឆ្នាំ២០០៩មកក្ដី។ ម្យ៉ាងទៀត SMEs មួយភាគធំ មិនមានរៀបចំរបាយការណ៍ហិរញ្ញវត្ថុផ្លូវការទេ ទោះជាក្រុមប្រឹក្សាគណនេយ្យជាតិ បានបង្កើតរបាយការណ៍គណនេយ្យសាមញ្ញមួយសម្រាប់ពួកគេក្ដី។

ឧបសគ្គចម្បងៗដែលរារាំងលទ្ធភាពរបស់ SME ដើម្បីទទួលបានហិរញ្ញវត្ថុ វាកើតចេញពីទំលាប់មិនល្អរបស់ពួកគេ គឺមានកង្វះស្តង់ដារគណនេយ្យ និងឋានៈមិនផ្លូវការ។ រដ្ឋាភិបាល បានដោះស្រាយបញ្ហាទាំងនេះនៅក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍ SME តាមរយៈការអនុម័តយុទ្ធសាស្ត្រ និងផែនការជាជំហានៗមួយ ដូច្នេះត្រូវមានការប្ដេជ្ញាចិត្តបន្ថែមទៀត ក្នុងការជំរុញឲ្យសហគ្រាសកាន់តែច្រើនមានឋានៈផ្លូវការ តាមរយៈការចុះបញ្ជី និងការកែលំអប្រព័ន្ធគ្រប់គ្រង និងរបាយការណ៍ហិរញ្ញវត្ថុ ឲ្យមានលក្ខណៈស្តង់ដារ។ ចំណុចនេះ ជាអាទិភាពទី១ របស់រដ្ឋាភិបាល ដើម្បីឆ្លើយតបនឹងកត្តាខាងតម្រូវការដែលរារាំងលទ្ធភាព SME ក្នុងការទទួលបានហិរញ្ញវត្ថុ។ វិធានការជាក់លាក់នានា ដើម្បីជំរុញ SMEs ឲ្យទទួលយកប្រព័ន្ធគ្រប់គ្រង និងឋានៈផ្លូវការ មិនស្ថិតក្នុងដែនស្រាវជ្រាវនៃរបាយការណ៍នេះទេ។

ដើម្បីញាំងឲ្យ ប្រព័ន្ធធានាខុសត្រូវផ្នែកឥណទានសម្រាប់ SMEs មានលក្ខណៈពេញលេញតាមច្បាប់ រដ្ឋាភិបាលគួរកសាងហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានា ទាំងផ្នែករឹង (ការិយាល័យឥណទានជាតិទទួលខុសត្រូវលើការប្រមូល និងគ្រប់គ្រងព័ត៌មានចំណាត់ថ្នាក់ឥណទានទូទាំងប្រទេស និងជំនួយទ្រទ្រង់ផ្នែកហិរញ្ញវត្ថុពីរដ្ឋាភិបាល ដើម្បីធានាមូលនិធិ) និងផ្នែកទន់ (ក្របខ័ណ្ឌច្បាប់ និងធនធានមនុស្ស) សម្រាប់ SMEs។ នៅពេលដែល SMEs នៅកម្ពុជា បានក្លាយជាក្រុមហ៊ុនមានប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុស្តង់ដារ ហើយស្ថាប័នហិរញ្ញវត្ថុ ក៏មានការយល់ដឹងកាន់តែប្រសើរពីទីផ្សារហិរញ្ញវត្ថុនោះ ភាពមិនស៊ីគ្នារវាងតម្រូវការ និងការផ្គត់ផ្គង់ហិរញ្ញប្បទានសម្រាប់ SMEs នឹងថយចុះជាបណ្ដើរៗ។

## ឯកសារយោង


Beck, T. & D.K. Asli (2006), "Small and Medium-Sized Enterprises: Access to Finance as a Growth Constraints", *Journal of Banking and Finance,* Vol.30 (11), pp. 2931-2943

Beck, T. (2007), "Financing Constraints of SMEs in Developing Countries: Evidence, Determinants and Solution," http://arno.uvt.nl/show.cgi?fid=95654 (accessed 27 June 2011)

Brother Investment Group (2010), *Banking Sector in Cambodia* (Phnom Penh: BIG Co., Ltd.)

http://www.big.com.kh/download/Banking%20Sector%20in%20Cambodia.pdf (accessed 2 May 2011)

Harner, S. M. (2003), *Financing SMEs in Cambodia: Why do Banks Find it so Difficult?*

http://www.ifc.org/ifcext/mekongpsdf.nsf/AttachmentsByTitle/PSDP+14/$FILE/PSDP-No-14-EN.pdf (accessed 2 May 2011)

IFC (2010), "Understanding the Cambodian Small and Medium Enterprise Needs for Financial Services and Products" (Phnom Penh: International Financial Corporation)

National Bank of Cambodia (2008), *Annual Report 2008* (Phnom Penh: NBC)

National Bank of Cambodia (2009), *Annual Supervision Report 2009* (Phnom Penh: NBC)

NIS (2009), *Nation-wide Establishment Listing of Cambodia 2009* (Phnom Penh: NIS)

NIS (2012), *Economic Census of Cambodia 2011* (Phnom Penh: NIS)

Oum, S., C. Harvie & D. Narjoko (eds.) (2011), "Small and Medium Enterprises' Access to Finance in Selected East Asian Economies", ERIA Research Project 2010, No. 11 (Jakarta: ERIA)

Petrick, M. (2004), "Farm Investment, Credit Rationing and Governmentally Promoted Credit Access in Poland: A Cross-Sectional Study", *Food Policy,* Vol.9, pp. 275–294

Saing C.H. (2009), "Trade Competitiveness of SMEs: Importance of Finance and Policy Options/Government Roles", *ARTNeT GMS Notes No.1*,

http://www.unescap.org/tid/artnet/mtg/ARTNeT%20GMS%20Notes%20No%201-%20Hang.pdf (accessed 27 June 2011)

SME Sub-committee (2005), *Small and Medium Development Framework*

http://www.usaid.gov/kh/documents/SME_Devel_Framework_English_Final_2005.pdf (accessed 2 May 2011)

SME Sub-committee (2006), *Annual Report* (Phnom Penh: SME Sub-committee)

Sohn, W. (2010), *Promoting Low-cost for Small and Medium-sized Enterprises and Rice Mills* (Korea: KDI)

Tong K. (2011), "Survey on Impact of the Global Financial and Economic Crisis on Employment in Cambodia" (Phnom Penh: CDRI)

World Bank (2010), *Cambodia Agribusiness Access to Finance Project: concept stage*

http://siteresources.worldbank.org/INTGENDER/Resources/Liberia_PID.pdf (accessed 30 June 2011)